ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

The Asia Foundation

# វេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះឆ្នាំ២០២៥
# «ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ននៅក្នុងបរិបទប្រែប្រួល ៖
# ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ»

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥

## សេចក្តីប្រកាសព័ត៌មានរួម
## ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងអង្គការមូលនិធិអាស៊ី គាំទ្រវិស័យស្រាវជ្រាវនៅកម្ពុជា

ថ្ងៃនេះ ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងអង្គការមូលនិធិអាស៊ី បានរៀបចំវេទិកាគោលនយោបាយថ្នាក់ជាតិឆ្នាំ ២០២៥ នៅរាជធានីភ្នំពេញ។ វេទិកានេះបានប្រមូលផ្តុំអ្នកចូលរួមជាង ២០០នាក់ មកពីខាងរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងតំណាងសហគមន៍ ដើម្បីពិភាក្សាអំពីរបៀបដែលវិស័យស្រាវជ្រាវនៅកម្ពុជាពង្រឹងការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ។

ក្នុងសុន្ទរកថារបស់ ឯកឧត្តមបណ្ឌិត វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមបណ្ឌិតបានគូសបញ្ជាក់ពីសារៈសំខាន់នៃការបញ្ចូលការស្រាវជ្រាវ និងទិន្នន័យ ទៅក្នុងដំណើរការតាក់តែងគោលនយោបាយជាតិ និងការធានាថាគោលនយោបាយទាំងនោះឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ជាពិសេស ក្រុមជនងាយរងគ្រោះបំផុត។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលី បានមានប្រសាសន៍ថា «អូស្ត្រាលី ជាអ្នកគាំទ្រដ៏យូរអង្វែងចំពោះវិស័យស្រាវជ្រាវ ដែលជាវិស័យមួយដ៏មានតម្លៃរបស់កម្ពុជា។ វេទិកាគោលនយោបាយថ្នាក់ជាតិនេះ គឺជាវេទិកាដ៏សំខាន់សម្រាប់ពង្រឹងទំនាក់ទំនងរវាងអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងសង្គមស៊ីវិល ហើយក៏ជាឱកាសមួយ ដើម្បីពិភាក្សាជាលក្ខណៈយុទ្ធសាស្ត្រអំពីតម្រូវការ និងការផ្គត់ផ្គង់ទិន្នន័យដែលអាចជឿទុកចិត្តបាន។ ការគាំទ្រវិស័យនេះ គឺជាមធ្យោបាយមួយផ្សេងទៀត ដែលអូស្ត្រាលី កំពុងចូលរួមចំណែក ដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ដែលជាការគាំទ្រដល់ការលើកកម្ពស់ភាពជាអ្នកដឹកនាំ ការអភិវឌ្ឍធនធានមនុស្ស ភាពធន់នឹងអាកាសធាតុ និងកំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។»

លោកស្រី Dolgion Aldar នាយិកាកម្មវិធីពន្លកចំណេះនៃ អង្គការមូលនិធិអាស៊ី បានមានប្រសាសន៍ថា «វិស័យស្រាវជ្រាវរបស់កម្ពុជាកំពុងមានការរីកចម្រើន ហើយវេទិកានេះកំពុងប្រែក្លាយចំណុចខ្លាំងទាំងនេះឱ្យទៅជាការសម្រេចចិត្តប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ។ វេទិកាថ្ងៃនេះរៀបចំឡើងដោយដៃគូ ដែលជាស្ថាប័នស្រាវជ្រាវរបស់កម្ពុជា

បង្ហាញពីការចូលរួមចំណែកក្នុងភាពជាដៃគូ និងការប្រើប្រាស់អ្នកជំនាញឯកទេសក្នុងស្រុក ក្នុងការពង្រឹងកិច្ចពិភាក្សាអំពីគោលនយោបាយជាតិឱ្យកាន់តែប្រសិទ្ធភាពថែមទៀត។»

វេទិកាគោលនយោបាយថ្នាក់ជាតិ គឺជាគំនិតផ្តួចផ្តើមមួយរបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា ដែលទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។ កម្មវិធីនេះពង្រឹងវិស័យស្រាវជ្រាវនៅកម្ពុជា តាមរយៈការកសាងកិច្ចសហប្រតិបត្តិការរវាងអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងសហគមន៍ ព្រមទាំងការបង្កើនការផ្តត់ផ្គង់ទិន្នន័យដែលគួរឱ្យទុកចិត្តបាន និងទាន់ពេលវេលា រួមទាំងការបញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការស្រាវជ្រាវ និងកិច្ចពិភាក្សានានា។

នៅក្នុងវេទិកានេះ ក៏មានការប្រកាសដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំរបស់កម្មវិធីពន្លកចំណេះស្តីពី គុណភាពនៃការស្រាវជ្រាវ និងកិច្ចពិភាក្សាប្រកបដោយបរិយាបន្ន និងមានការរៀបចំជាកិច្ចពិភាក្សាពេញអង្គ និងកិច្ចពិភាក្សាតាមក្រុមលើប្រធានបទសំខាន់ៗ ដូចជា ការប្រែប្រួលអាកាសធាតុ ទេសន្តរប្រវេសន៍ ការអភិវឌ្ឍជនបទ ការចូលរួមដែលដឹកនាំដោយយុវជន និងសមត្ថភាពក្នុងការស្រាវជ្រាវ ជាដើម។ លើសពីនេះ ក៏មានពិធីប្រគល់ពានរង្វាន់បរិយាបន្ន ដើម្បីអបអរចំពោះការរួមចំណែកលេចធ្លោក្នុងការស្រាវជ្រាវ ការទំនាក់ទំនង និងកិច្ចសន្ទនាប្រកបដោយបរិយាបន្នផងដែរ។

វិស័យស្រាវជ្រាវ និងកិច្ចខិតខំប្រឹងប្រែងរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត ក្នុងការរៀបចំគោលនយោបាយឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប គឺជាគន្លឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា ខណៈដែលកម្ពុជាកំពុងឈានទៅរកការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក៖

ស្ថានទូតអូស្ត្រាលី៖ Media.Cambodia@dfat.gov.au

កម្មវិធីពន្លកចំណេះ៖ Ponlok.Chomnes@asiafoundation.org